ព្រឹទ្ធសភាវ៉ាស៊ីនតោន
សមាជិកព្រឹទ្ធសភា **ដុន ប៊ិនតុន** (Don Benton)

ថ្ងៃទី ១១ កញ្ញា ២០១៥

**សម្ដេច ហ៊ុន សែន**
នាយករដ្ឋមន្ត្រី
ព្រះរាជាណាចក្រកម្ពុជា
ភ្នំពេញ

សម្ដេចនាយករដ្ឋមន្ត្រី **ហ៊ុន សែន**

សូមសម្ដេចទទួលការស្វាគមន៍យ៉ាងកក់ក្ដៅពីសហរដ្ឋអាមេរិក។ ខ្ញុំសូមឆ្លៀតឱកាសនេះ សំដែងក្នុងនាមខ្ញុំផ្ទាល់នូវការអបអរសាទរជូនសម្ដេច ចំពោះការដឹកនាំដែលគួរយកជាគំរូរបស់រដ្ឋាភិបាលសម្ដេច ក្នុងការរក្សាការពារសន្តិសុខ និងអធិបតេយ្យភាពនៃព្រះរាជាណាចក្រកម្ពុជា។

ការការពារ និងការរក្សាបូរណភាពទឹកដីរបស់ប្រទេសជាតិ ស្ថិតក្នុងចំណោមកាតព្វកិច្ចសំខាន់បំផុតដែលអ្នកដឹកនាំប្រទេសជាតិត្រូវតែធ្វើ។ ជាការពិតណាស់ ការការពារព្រំដែនរបស់ប្រទេសជាតិគឺជាមូលដ្ឋាននៃប្រព័ន្ធអន្តរជាតិសម័យទំនើបទាំងមូលរបស់យើង (ដូចមានចែងក្នុងធម្មនុញ្ញរបស់អង្គការសហប្រជាជាតិ)។ បើសិនជាគ្មានការកំណត់ព្រំដែនប្រទេសជាតិអោយបានច្បាស់លាស់នោះទេ គឺគ្មានប្រទេសណាមួយអាចការពារផលប្រយោជន៍ជាមូលដ្ឋានរបស់ពលរដ្ឋគេបានទេ ឬផ្ដល់ការដឹកនាំដ៏ឈ្លាសវៃក្នុងវិស័យសំខាន់ៗដូចជាការអភិវឌ្ឍន៍សេដ្ឋកិច្ច ការថយចុះផ្នែកបរិស្ថាន ឬការការពារវប្បធម៌បុរាណ។

ជាពិសេស ខ្ញុំបានតាមដានយ៉ាងយកចិត្តទុកដាក់នូវការវាយប្រហារដោយគ្មានមូលដ្ឋានចំពោះរដ្ឋាភិបាលរបស់សម្ដេច អំពីបញ្ហាខ្សែបន្ទាត់ព្រំដែនជាតិនៃព្រំដែនភាគខាងកើតរបស់ប្រទេសសម្ដេច។ បើទោះបីជារដ្ឋាភិបាលរបស់សម្ដេច ប្រើប្រាស់នូវបច្ចេកវិទ្យាទំនើបដូចជាGPSយ៉ាងណាក៏ដោយ (មិនចាំបាច់លើកឡើងពីការសិក្សាទៅលើផែនទីប្រវត្តិសាស្ត្រជាក់ស្ដែងរបស់សហរដ្ឋអាមេរិក បារាំង និងអង្គការសហប្រជាជាតិ) ការវាយប្រហារដោយហេតុផលនយោបាយនៅតែបន្ត។ នេះគឺជាប្រការដ៏អកុសលបំផុត។

តាមរយៈរបាយការណ៍នានាដែលខ្ញុំបានអាន រដ្ឋបាលរបស់សម្ដេចបានដោះស្រាយបញ្ហាយ៉ាងសកម្មខ្លាំងក្លាបំផុត រួមទាំងការចរចាទល់មុខគ្នាជាមួយសាធារណរដ្ឋសង្គមនិយមវៀតណាមកាលពីខែកក្កដាកន្លងទៅនេះ។ តាមខ្ញុំដឹង ការចរចាទាំងនេះទទួលបានលទ្ធផលផ្លែផ្កា ប៉ុន្តែការងាររបស់គណៈកម្មាធិការចំរុះកិច្ចការព្រំដែនកម្ពុជា-វៀតណាម ត្រូវបន្តទៅទៀត។ ការចរចាទ្វេភាគីទាំងនេះ មានសារៈសំខាន់ណាស់សំរាប់ថែរក្សា និងបង្កើនសន្តិភាព និងវិបុលភាពដែលព្រះរាជាណាចក្រសំរេចបាន ចាប់តាំងពីការបោះឆ្នោតដោយសេរីលើកទី១កាលពី២៥ឆ្នាំមុន។

ខ្ញុំសង្ឃឹមថា នៅពេលនេះ បណ្ដាប្រទេសដែលបានរៀបរាប់ខាងលើ បានផលិតឯកសារប្រភពដើមដែលគាំទ្រដល់គោលនយោបាយបោះបង្គោលព្រំដែនរបស់រដ្ឋាភិបាលសម្ដេច អារ្យធម៌ខ្មែរបុរាណនឹងអាចវិលត្រឡប់ទៅផ្ដោតការយកចិត្តទុកដាក់លើការជំរុះជំរុញ ការធ្វើប្រជាធិបតេយ្យូបនីយកម្ម និងពាណិជ្ជកម្មអន្តរជាតិ ដែលនឹងបង្កើនគុណភាពជីវភាពសំរាប់ប្រជាជនកម្ពុជា ។

សហការីរបស់ខ្ញុំ និងខ្លួនខ្ញុំផ្ទាល់ត្រៀមរួចជាស្រេច ដើម្បីជួយដល់ប្រជាជនកម្ពុជាតាមមធ្យោបាយដែលយើងអាចធ្វើបាន។

ដោយក្ដីស្មោះស្ម័គ្រពីខ្ញុំ

សមាជិកព្រឹទ្ធសភា **ដុន ប៊ិនតុន**
វ៉ានឃូវើ វ៉ាស៊ីនតោន